## ខេត្តតាកែវ

## សក្តានុពលវិនិយោគ

ខែ មករា ឆ្នាំ ២០១០

USAID
ជំនួយពីពលរដ្ឋអាមេរិក




# ខេត្តតាកែវ

## ជម្រើសអាជីវកម្ម













**បញ្ជាក់:**

ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលអាមេរិកឡើយ ។




# របាយការណ៍វិនិយោគនៅខេត្តតាកែវ


**សារស្វាគមន៍ពីថ្នាក់ដឹកនាំខេត្ត** .................................................. ២

**ចំណុចខ្លាំងថ្នាក់ជាតិ** .................................................. ៣

បើកចំហចំពោះអាជីវកម្ម

កំលាំងពលកម្មតម្លៃទាប និងមានផលិតភាព

ទីតាំងជាយុទ្ធសាស្ត្រក្នុងតំបន់

**ហេតុអ្វីបានជាជ្រើសរើសយកខេត្តតាកែវ?** .................................................. ៤

១. ទីតាំងជាយុទ្ធសាស្ត្រ

២. កម្លាំងពលកម្មមានចំណេះដឹង - អត្រាចុះឈ្មោះចូលរៀនខ្ពស់បំផុតនៅប្រទេសកម្ពុជា

៣. តំបន់សេដ្ឋកិច្ចពិសេសឈានមុខដើម្បីលើកទឹកចិត្តដល់ការធ្វើពាណិជ្ជកម្ម អាចរកចំណេញបាន

៤. ការផ្គត់ផ្គង់អគ្គិសនីមានលក្ខណៈប្រកួតប្រជែង

៥. វិស័យសេវាកម្មហិរញ្ញវត្ថុមានការអភិវឌ្ឍន៍យ៉ាងល្អ

៦. ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដ៏ល្អប្រសើរ

**វិស័យសំខាន់ៗរបស់ខេត្ត** .................................................. ៦

**កាលានុវត្តភាពអាជីវកម្ម** .................................................. ៧

**សកម្មភាពអភិវឌ្ឍន៍កំពុងដំណើរការ** .................................................. ៧

**ត្រូវការស្វែងយល់បន្ថែមទៀតទេ?** .................................................. ៨


របាយការណ៍វិនិយោគនេះផលិតដោយ Emerging Markets Consulting សំរាប់ គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា ដែលអនុវត្តគំរោងដោយអង្គការ DAI ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ និងមានការចូលរួមសហការពីសាលាខេត្តសៀមរាប និងគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។








# សារស្វាគមន៍ពីថ្នាក់ដឹកនាំខេត្ត

ខេត្តតាកែវមានឈ្មោះល្បីជាជង្រុកស្រូវនៃប្រទេសកម្ពុជា។ ជាក់ស្តែងទិន្នផលស្រូវប្រចាំឆ្នាំពីខេត្តដ៏តូចរបស់យើងអាចចិញ្ចឹមប្រជាជនបានមួយភាគបួននៃប្រទេសកម្ពុជា។ ក្រៅពីស្រូវ ខេត្តរបស់យើងក៏មានសក្តានុពលផ្សេងទៀតដែរ។

ដោយសារខេត្តមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេ ក្រៅពីរាជធានីភ្នំពេញ និងខេត្តកណ្តាល យើងគឺជាខេត្តឈានមុខបំផុតមួយ ក្នុងចំណោមខេត្តឈានមុខនានានៅក្នុងប្រទេសកម្ពុជា ដោយមានលក្ខណៈល្អប្រសើរសម្រាប់រក្សានិរន្តរភាពអាជីវកម្ម ដែលអាចរកប្រាក់ចំណេញបាន។ មោទនភាពនៃខេត្តរបស់យើងរួមមានៈ កម្រិតអត្រានៃភាពក្រីក្រទាប ហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ ប្រជាជនមានកម្រិតអប់រំខ្ពស់ និងកម្លាំងពលកម្មមានជំនាញ វត្តមានធនាគារល្អ និងទីផ្សារក្នុងស្រុករឹងមាំ។ ដើម្បីបន្តបង្កើនគ្រឹះសេដ្ឋកិច្ចរបស់យើង និងពង្រឹងកេរ្តិ៍ឈ្មោះរបស់យើងក្នុងនាមជាទីតាំងទើបលេចឡើងសម្រាប់ការវិនិយោគ អាជ្ញាធរខេត្តតាកែវនឹងបន្តធ្វើការមិនឈប់ឈរដើម្បីពង្រឹងបរិយាកាសអាជីវកម្ម។

យើងមានសេចក្តីរំភើបរីករាយចំពោះសក្តានុពលទាំងនេះ ដើម្បីពង្រីក និងពង្រឹងមូលដ្ឋានឧស្សាហកម្មរបស់យើង ហើយសូមស្វាគមន៍ដោយបើកចំហចំពោះអ្នកវិនិយោគថ្មីៗទាំងក្នុងស្រុក និងបរទេស។

ខ្ញុំទន្ទឹងរង់ចាំធ្វើការជាមួយអ្នកវិនិយោគថ្មីៗ ដើម្បីជួយពង្រីកអាជីវកម្មរបស់ពួកគេ និងធ្វើអោយខេត្តរបស់យើងមានឧត្តមភាពកាន់តែខ្លាំងក្លាឡើងថែមទៀត។

សូមទទួលនូវការស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

តាកែវ ខែ មករា ឆ្នាំ ២០១០
អភិបាលខេត្តតាកែវ



**ឯកឧត្តម ស្រី បេន**





# ចំណុចខ្លាំងថ្នាក់ជាតិ

អស់រយៈពេលជាងមួយទសវត្សរ៍កន្លងទៅនេះប្រទេសកម្ពុជាបានលេចឡើងជាប្រទេសក្នុងតំបន់ដែលមានតួនាទីរស់រវើក និងរឹងមាំជាមួយនឹងកេតនភណ្ឌជាមូលដ្ឋានជាច្រើន ដែលចាំបាច់សម្រាប់ការអភិវឌ្ឍន៍និងកំណើនអាជីវកម្មដោយជោគជ័យ ។

## បើកចំហចំពោះអាជីវកម្ម

- ពន្ធអាជីវកម្មទាប - ពន្ធ២០% លើផលចំណេញអាជីវកម្ម (អាចអនុគ្រោះពន្ធរហូតដល់ ៥ ឆ្នាំ ចំពោះការខាតបង់) ។
- គ្មានការដាក់កំហិតលើម្ចាស់កម្មសិទ្ធិជាជនបរទេស (លើកលែងតែកម្មសិទ្ធិដីធ្លី) ។
- នាំមុខប្រទេសចិន ឥណ្ឌា វៀតណាម និងឥណ្ឌូនេស៊ី ចំពោះសេរីភាពសេដ្ឋកិច្ច[1] ។
- ប្រព្រឹត្តស្មើភាពចំពោះអ្នកវិនិយោគទាំងអស់ ។
- នាំមុខប្រទេសហ្វីលីពីន ចិន និងវៀតណាម ចំពោះការការពារអ្នកវិនិយោគ[2] ។
- គ្មានការត្រួតពិនិត្យតម្លៃលើទំនិញ ឬសេវាកម្ម ។
- គ្មានការត្រួតពិនិត្យលើការប្តូររូបិយវត្ថុបរទេស ឬគ្មានការដាក់កំហិតលើការប្តូរប្រាក់ ។
- គ្មានការដាក់កំហិតលើការបង្វិលដើមទុនទៅប្រទេសរបស់អ្នកវិនិយោគវិញ ។
- ជាប្រទេសដំបូងគេក្នុងចំណោមប្រទេសដែលមានការអភិវឌ្ឍន៍តិច (LDC) ដែលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។
- គ្មានការដាក់កំហិតលើបរិមាណពាណិជ្ជកម្ម បន្ថយរបាំងពន្ធគយ ។ ប្រទេសកម្ពុជាទទួលបានការអនុគ្រោះពន្ធគយ និងកូតាទៅកាន់ទីផ្សារធំៗរបស់ពិភពលោក (ដូចជាសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ប្រទេសជប៉ុន និងប្រទេស សមាជិកអាស៊ានជាច្រើន) ។
- អាជ្ញាធរខេត្តមានសិទ្ធិអំណាចក្នុងការអនុម័តការវិនិយោគ ក្រោមទឹកប្រាក់ ២ លានដុល្លារអាមេរិក ដើម្បីជំរុញការចាប់ផ្តើមអភិវឌ្ឍអាជីវកម្មអោយបានឆាប់រហ័ស ។

*"ប្រទេសកម្ពុជាកំពុងបើកចំហទាំងស្រុងចំពោះអាជីវកម្ម ហើយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងព្យាយាម អោយអស់ពីលទ្ធភាព ដើម្បីធានាបាននូវបរិយាកាសអនុគ្រោះ និងភាពជោគជ័យ សម្រាប់រាល់សហគ្រាសទាំងអស់នៅក្នុងប្រទេសកម្ពុជា" ។*

- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## កម្លាំងពលកម្មតម្លៃទាប និងមានផលិតភាព

ដោយប្រៀបធៀបទៅនឹងអ្នកប្រកួតប្រជែងជាច្រើននៅក្នុងតំបន់ ប្រទេសកម្ពុជាមានអត្រាប្រាក់ឈ្នួលប្រកួតប្រជែង ហើយកម្លាំងពលកម្មមានផលិតភាពខ្ពស់ ធ្វើអោយប្រទេសកម្ពុជាក្លាយជាទិសដៅដ៏ទាក់ទាញសម្រាប់ឧស្សាហកម្ម ដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ។

កាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ កម្លាំងពលកម្មរបស់ប្រទេសកម្ពុជាបានកើនឡើងជាង ៥០% ច្រើនជាងទ្វេដងនៃអត្រានៅក្នុងប្រទេសអាស៊ានផ្សេងទៀត[3] ។ ដោយមានប្រជាជនវ័យក្មេងច្រើន (ប្រជាជនពាក់កណ្តាលមានអាយុក្រោម ២០ ឆ្នាំ) កម្លាំងពលកម្មនេះនឹងបន្តកើនឡើង ។

## តម្លៃពលកម្មនៅក្នុងឧស្សាហកម្មកាត់ដេរ (ឆ្នាំ២០០៨)

| ប្រទេស | ដុល្លារអាមេរិកក្នុងមួយម៉ោង រួមទាំងបន្ទុកសង្គម |
|---|---|
| ថៃ | 1.29-1.36 |
| ម៉ាឡេស៊ី | 1.18 |
| ចិនដីគោក | 1.08 |
| ចិនតំបន់ឆ្នេរ | 0.86-0.94 |
| ចិនជនបទ | 0.55-0.8 |
| ឥណ្ឌូនេស៊ី | 0.44 |
| វៀតណាម | 0.38 |
| កម្ពុជា | 0.33 |

*ប្រភព : Jassin-O'Rourke Group ការវិភាគតម្លៃពលកម្មផលិតសម្លៀកបំពាក់ជាសាកល ឆ្នាំ២០០៨*

*"ដូចជាប្រទេសចិន និងឥណ្ឌា នៅក្នុងសម័យកាលមុនៗដែរ ប្រទេសកម្ពុជាត្រូវបានកំណត់ថាជាកន្លែងដែលរំពឹងទុកពេលអនាគតសម្រាប់ការវិនិយោគខាងការផលិត ជាពិសេសដោយសារតែវត្តមានដ៏ទូលំទូលាយ នៃពលកម្មតម្លៃថោក និងបុព្វលាភហានិភ័យរបស់ប្រទេសទាប...ប្រទេសកម្ពុជាក៏ទទួលបានអត្ថប្រយោជន៍ពីភាពស្ថិតនៅជិតល្មមទៅនឹងឆ្នេរខាងលិចនៃសហរដ្ឋអាមេរិក" ។*

- PriceWaterhouseCoopers.

## ទីតាំងជាយុទ្ធសាស្ត្រក្នុងតំបន់

ប្រទេសកម្ពុជាមានទីតាំងយ៉ាងល្អឥតខ្ចោះនៅចំកណ្តាលតំបន់ប្រកបដោយថាមភាពបំផុតនៅក្នុងពិភពលោក ។ ដោយស្ថិតនៅជាប់ប្រទេសថៃ និងវៀតណាមប្រទេសកម្ពុជាគឺជា ផ្នែករបៀងនៃដែនសេដ្ឋកិច្ចភាគខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គលាតសន្ធឹង ពីទីក្រុងហូជីមិញ ដល់ទីក្រុងបាងកក ។ ដោយសារតែទីតាំងជាយុទ្ធសាស្ត្រនេះ ប្រទេសកម្ពុជាទទួលបានការគាំទ្រពីអន្តរជាតិគួរអោយកត់សម្គាល់ នៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួន ដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេស និងជាមួយប្រទេសជិតខាង ។ ជាលទ្ធផលការធ្វើពាណិជ្ជកម្មជាមួយប្រទេសវៀតណាម និងថៃកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ។

---

1. *មូលនិធិបេតិកភណ្ឌ សន្ទស្សន៍សេរីភាពសេដ្ឋកិច្ចឆ្នាំ២០០៩ http://www.heritage.org/index/*
2. *ធនាគារពិភពលោក ស្តីពីការធ្វើអាជីវកម្មឆ្នាំ២០០៩ http://www.doingbusiness.org/*
3. *អង្គការពលកម្មអន្តរជាតិ "ពលកម្ម និងនិន្នាការសង្គមនៅក្នុងអាស៊ាន ឆ្នាំ២០០៧ - សមាហរណកម្ម បញ្ហាប្រឈម និងកាលានុវត្តភាព" ឆ្នាំ២០០៧*








*"អ្នកមានទីក្រុងធំៗបំផុតពីរនៅអាស៊ីអមសងខាងអ្នក។ អ្នកមានប្រជាជន១៥លាននាក់នៅទីក្រុងបាងកក និង៨លាននាក់នៅទីក្រុងហូជីមិញ ហើយអ្វីៗនឹងកើតមានកាន់តែច្រើនឡើងៗ នៅចន្លោះទីក្រុងទាំងពីរនេះ។*

- Edward Hopkins, CB Richard Ellis Group Inc.

# ហេតុអ្វីបានជាជ្រើសរើសយកខេត្តតាកែវ?

## ១. ទីតាំងជាយុទ្ធសាស្ត្រ

ទីតាំងខេត្តតាកែវមានលក្ខណៈប្រសើរបំផុតសម្រាប់អាជីវកម្មនៅប្រទេសកម្ពុជា។ ខេត្តរបស់យើងចំណាយពេលបើកបរតែ ១ម៉ោងកន្លះប៉ុណ្ណោះពីរាជធានីភ្នំពេញ និង ២ម៉ោងកន្លះ ពីខេត្តព្រះសីហនុ ហើយមានព្រំដែនសំខាន់ជាប់ប្រទេសវៀតណាមផងដែរ។

### បណ្តាញផ្លូវថ្នល់

ខេត្តតាកែវតភ្ជាប់ដោយកំណាត់ផ្លូវជាតិចំនួនបួន មានប្រវែងជាង ១៦៩គីឡូម៉ែត្រនៅក្នុងខេត្ត។ ខេត្តមានពលរដ្ឋរស់នៅច្រើនកកកុញ យើងមានប្រវែងផ្លូវជាតិឆ្លងកាត់វែងជាងខេត្តនានាក្នុងផ្ទៃក្រឡាមួយគីឡូម៉ែត្រការេដើមួយរយគីឡូម៉ែត្រការេ (៤,៧ គីឡូម៉ែត្រក្នុង ១០០ គីឡូម៉ែត្រការ៉េ)។

ទីរួមខេត្តតាកែវមានចម្ងាយតែ ៧៨ គីឡូម៉ែត្រ និងរយៈពេលបើកបរ ១ ម៉ោងកន្លះប៉ុណ្ណោះពីរាជធានីភ្នំពេញ តាមផ្លូវជាតិលេខ២។ ជាមធ្យមប្រចាំយានយន្តជាង ៧.១០០ គ្រឿងធ្វើដំណើរតាមផ្លូវនេះនៅក្នុងឆ្នាំ២០០៧។

ការធ្វើដំណើរទៅកាន់កំពង់ផែសមុទ្រជ្រៅនៅខេត្តព្រះសីហនុ តាមផ្លូវជាតិលេខ ៣ ចំណាយពេល ២ ម៉ោងកន្លះ។ កំពង់ផែឯកជនថ្មីមួយកំពុងត្រូវបានសាងសង់នៅក្នុងខេត្តកំពត ដោយចំណាយពេលជាងមួយម៉ោងប៉ុណ្ណោះទៅកាន់ទីនោះ។

ការធ្វើពាណិជ្ជកម្មជាមួយប្រទេសវៀតណាមត្រូវបានសម្រួល ដោយច្រកព្រំដែនចំនួន ៣កន្លែង (១កន្លែងគឺច្រកអន្តរជាតិភ្នំដិននិង១កន្លែងទៀតគឺច្រកទ្វេភាគីកំពង់ក្រសាំងនិងច្រកទ្វាតំបន់ព្រំដែនបាក់ដៃ)។ ផ្លូវជាតិលេខ ២ តភ្ជាប់ខេត្តតាកែវទៅកាន់ព្រំដែនប្រទេសវៀតណាម នៅភ្នំដិនដែលមានរយៈពេលបើកបរតែ ៤៥ នាទីប៉ុណ្ណោះពីទីរួមខេត្តតាកែវ ដែលកាលពីប៉ុន្មានឆ្នាំមុន ចំណាយពេលជិត ៣ ម៉ោង។ ចរាចរណ៍ប្រចាំថ្ងៃជាមធ្យមតាមកំណាត់ផ្លូវនេះមាន យានជំនិះជិត ៥.០០០ នៅក្នុងឆ្នាំ២០០៧ ហើយវាហាក់ដូចជា កើនឡើងគួរអោយកត់សម្គាល់ជាមួយនឹងការអភិវឌ្ឍន៍នៃតំបន់ព្រំដែនរបស់ខេត្ត ព្រមជាមួយនឹងការផ្លាស់ប្តូរដែលបានធ្វើ អោយកាន់តែមានភាពងាយស្រួលសម្រាប់ជនជាតិវៀតណាមក្នុងការចូលមកប្រទេសកម្ពុជា។

សភាពផ្លូវថ្នល់នៅទូទាំងខេត្ត ត្រូវបានកែលម្អអោយប្រសើរឡើងគួរអោយកត់សម្គាល់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយអាជីវកម្មក្នុងមូលដ្ឋានបានរាយការណ៍ឱ្យដឹងថាមានការកាត់បន្ថយពេលវេលាដឹកជញ្ជូន និងថ្លៃចំណាយរហូតដល់ ៣០%។

### ផ្លូវដែក

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្តើមការងារជួសជុលកែលម្អខ្សែផ្លូវដែកពីរាជធានីភ្នំពេញទៅកាន់ខេត្តព្រះសីហនុដោយឆ្លងកាត់តាមខេត្តតាកែវ។ខ្សែផ្លូវដែកនេះនឹងជួយសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្មអោយកាន់តែប្រសើរ ឡើងថែមទៀត។ ជាពិសេស តម្លៃនៃការដឹកជញ្ជូនទំនិញទៅ និងមកពីកំពង់ផែខេត្តព្រះសីហនុ តាមផ្លូវដែកដែលគេរំពឹងថាមានលក្ខណៈប្រកួតប្រជែងយ៉ាងខ្លាំង។ ខ្សែផ្លូវដែកទៅកាន់រាជធានីភ្នំពេញពីទីរួមខេត្តតាកែវមានចំងាយប្រហែល ៧៥គីឡូម៉ែត្រ។

### ផ្លូវទឹក

ទីរួមខេត្តតាកែវ តភ្ជាប់ទៅប្រទេសវៀតណាមតាមដងស្ទឹងតាកែវ ដែលផ្តល់នូវផ្លូវដឹកជញ្ជូនបន្ថែមទៀតមានផលប្រយោជន៍ច្រើន។

លើសពីនេះទៅទៀត ផ្លូវទឹកកំពុងត្រូវបានជួសជុលកែលំអ ដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មរវាងប្រទេសវៀតណាម និងតំបន់សេដ្ឋកិច្ចពិសេសដូងឈីវ នៅខេត្តតាកែវ។

## ២. កម្លាំងពលកម្មមានចំណេះដឹង - អត្រាចុះឈ្មោះចូលរៀនខ្ពស់បំផុតនៅប្រទេសកម្ពុជា

សិស្សជាង ២៤៦.០០០នាក់ ចូលរៀនសាលាបឋមសិក្សាទាំង ៣៧៣ និងសាលាមធ្យមសិក្សា ១០៨ របស់យើង។ ក្នុងអត្រា ៣០% នៃប្រជាជនសរុប នេះគឺជាភាគរយខ្ពស់បំផុតនៅប្រទេសកម្ពុជា ដែលបង្ហាញអំពី ការប្តេជ្ញាចិត្តរបស់ខេត្តក្នុងការអប់រំយុវជនរបស់យើងដើម្បី និងធានា បាននូវកម្លាំងពលកម្មក្នុងស្រុករឹងមាំ និងមានចំណេះដឹងជ្រៅជ្រះ។

| គ្រឹះស្ថានអប់រំ | ចំនួន |
|---|---|
| មត្តេយ្យសាលា | 170 |
| សាលាបឋមសិក្សា | 373 |
| សាលាមធ្យមសិក្សា | 108 |
| សាកលវិទ្យាល័យ | 4 |
| សាលាគរុកោសល្យ | 1 |
| សាលាបណ្តុះបណ្តាលភាសា | 4 |
| វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ | 3 |

# ហេតុអ្វីបានជាជ្រើសរើសយកខេត្តតាកែវ?





សាកលវិទ្យាល័យចំនួនបួន ចូលរួមបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងខេត្តរបស់យើងនិងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈចំនួនបី កំពុងបង្រៀនជំនាញខាងជួសជុលរថយន្ត គ្រឿងចក្រកសិកម្ម អគ្គិសនី និងអេឡិចត្រូនិច ការរចនាក្រាហ្វិច បដិសណ្ឋារកិច្ច និងមុខជំនាញផ្សេងទៀត។

ខេត្តតាកែវគឺជាប្រភពកម្លាំងពលកម្មចម្បងនៃវិស័យផលិតកម្មដែលរីកលូតលាស់យ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជាហើយ កម្មករ-កម្មការិនីរោងចក្រកាត់ដេរមានជំនាញភាគច្រើនមកពីខេត្តតាកែវ។ ឥឡូវនេះ រោងចក្រកំពុងរើទីតាំងទៅកាន់ខេត្តតាកែវ ដើម្បីខិតទៅកាន់តែជិតប្រភពកម្លាំងពលកម្ម និងទាញអត្ថប្រយោជន៍ពីកេតនភណ្ឌ ផ្សេងទៀតរបស់ខេត្ត។

ឧទាហរណ៍មួយនៃនិន្នាការនេះ ស្ថាប័នមីក្រូហិរញ្ញវត្ថុមួយដែលកំពុងដំណើរការនៅក្នុងខេត្តបានរាយការណ៍ឱ្យដឹងថា៩៧% នៃបុគ្គលិករបស់ខ្លួននៅខេត្តមានប្រភពចេញមកពីខេត្តរបស់យើងដែលនេះមិនដែលធ្លាប់មាននៅក្នុងខេត្តផ្សេងៗទៀត នៃប្រទេសកម្ពុជា។

កម្លាំងពលកម្មមិនមានជំនាញមានតម្លៃប្រហែល ៣៥ ទៅ ៧៥ ដុល្លារ ក្នុងមួយខែ (បូកទាំងម្ហូបអាហារ និងកន្លែងស្នាក់នៅក្នុងករណីមួយចំនួន។ កម្លាំងពលកម្មមានជំនាញ និងបទពិសោធន៍ខ្ពស់ មានតម្លៃចាប់ពី ១២០ ដុល្លារ ឡើងទៅក្នុងមួយខែ។

ខេត្តតាកែវផ្តល់ដល់អាជីវកម្មនានានូវធនធានមនុស្សឈានមុខ ដើម្បីគាំទ្រដល់កំណើនរបស់អាជីវកម្មទាំងនោះ។ យើងមើលចំណុចនេះថាជាកម្លាំងប្រកួតប្រជែងមួយយ៉ាងសំខាន់របស់យើង ដែលវិនិយោគិននៅក្នុងខេត្តអាចធ្វើអោយវាក្លាយជាកម្លាំងប្រកួតប្រជែងមួយរបស់ពួកគេផងដែរ។

## ៣. តំបន់សេដ្ឋកិច្ចពិសេសឈានមុខដើម្បីលើកទឹកចិត្តដល់ការធ្វើពាណិជ្ជកម្មអាចរកចំណេញបាន

ខេត្តតាកែវ គឺជាទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេស ដួង ឈីវ។ មានទីតាំងស្ថិតនៅស្រុកគីរីវង់ តំបន់ដែលមានផ្ទៃក្រឡា ៧៩ហិកតារនេះស្ថិតនៅជិតច្រកព្រំដែនអន្តរជាតិភ្នំដិនជាប់ប្រទេសវៀតណាម ហើយមានរយៈពេលបើកបរប្រហែល ៤៥ នាទីពីទីរួមខេត្តតាកែវ។ តំបន់សេដ្ឋកិច្ចពិសេស(SEZ) នៅជិតទៅនឹងកំពង់ផែធំៗរបស់ប្រទេសវៀតណាមនៅខេត្ត អានយ៉ាង និងកំពង់ផែ កាន់ ធឺ ដោយមានដៃព្រែកធំមួយដែលតភ្ជាប់តំបន់សេដ្ឋកិច្ចពិសេស ទៅនឹងព្រែក វិន តេ(Vinh Te)នៅក្នុងប្រទេសវៀតណាម។ ព្រែកនេះផ្តល់អំណោយផលដល់ការដឹកជញ្ជូនតាមផ្លូវទឹក ពីកម្ពុជាទៅកាន់កំពង់ផែទាំងពីរនេះ។

តំបន់សេដ្ឋកិច្ចពិសេសផ្តល់នូវអត្ថប្រយោជន៍បន្ថែមដូចខាងក្រោម :

- ការចេញអាជ្ញាប័ណ្ណមានលក្ខណៈងាយស្រួល
- មិនយកពន្ធក្នុងរយៈពេលពី ៣ ទៅ ៦ ឆ្នាំ
- ការលើកលែងពន្ធលើការនាំចូលទាំងស្រុង
- មិនយកពន្ធលើការនាំចេញ
- ហេដ្ឋារចនាសម្ព័ន្ធលំដាប់ថ្នាក់ពិភពលោក
- ថ្លៃអគ្គិសនី និងទឹកថោកជាង ១០%

**កម្ពុជា-ខេត្តតាកែវ រយៈពេលធ្វើដំណើរតាមរថយន្តទៅកាន់ទីរួមខេត្តឬក្រុងនានា**




សញ្ញាព្រួញតំណាងឱ្យរយៈពេលនៃការធ្វើដំណើរដោយរថយន្តគិតជាម៉ោងរយៈពេលធ្វើដំណើរទៅកាន់ទីក្រុងបាងកក និង ហូជីមិញ មិនរាប់បញ្ចូលរយៈពេលឆ្លងកាត់ព្រំដែនទេ

តំបន់សេដ្ឋកិច្ចពិសេសនឹងក្លាយជាទីតាំងនៃរោងចក្រកែច្នៃកសិផល រួមទាំងរោងម៉ាស៊ីនកិនស្រូវដែលមានគោលដៅធ្វើជាទីផ្សារនាំចេញ។

## ៤. ការផ្គត់ផ្គង់អគ្គិសនីមានលក្ខណៈប្រកួតប្រជែង

ខេត្តតាកែវបម្រើជូននូវអគ្គិសនីបានយ៉ាងល្អគួរជាទីទុកចិត្ត ហើយការផ្គត់ផ្គង់ត្រូវបានរំពឹងថានឹងកើនឡើងនៅក្នុងរយៈពេល ប៉ុន្មានឆ្នាំខាងមុខនេះ។

ប្រភពអគ្គិសនីសំខាន់បច្ចុប្បន្នរបស់ខេត្តគឺនាំចូលពីប្រទេសវៀតណាមផង និងបានមកពីម៉ាស៊ីនដើរដោយប្រេងម៉ាស៊ូតក្នុងស្រុកផង។ ការផ្គត់ផ្គង់អគ្គិសនីត្រូវបានកែលម្អអោយប្រសើរឡើងកាលពីពេលថ្មីៗកន្លងទៅនេះ ដោយបានបញ្ចប់ការស្ថាបនាខ្សែបញ្ជូនតង់ស្យុងថ្មីមួយកម្លាំង ២២០ គីឡូវ៉ុល (ជាចុងក្រោយខ្សែនេះនឹងត្រូវពង្រីកដល់រាជធានីភ្នំពេញ)។ ប្រទេសកម្ពុជា ត្រូវរំពឹងថានឹងនាំចូលអគ្គិសនី ៨០ មេហ្គាវ៉ាត់ជាដំបូង ហើយនឹងពង្រីកដល់ ២០០ មេហ្គាវ៉ាត់ ក្នុងរយៈពេលបីឆ្នាំ។

ខេត្តក៏មានរោងចក្រជាកម្មសិទ្ធិរបស់រដ្ឋចំនួន៤នៅក្នុងទីរួមខេត្តនិងរោងចក្រថាមពលឯកជនតូចៗចំនួន ៣០ ស្ថិតនៅក្នុងស្រុកផ្សេងៗជុំវិញខេត្ត។

លើសពីនេះទៅទៀត ចាប់ពីឆ្នាំ២០១១ តទៅខេត្តតាកែវនឹងទទួលបានអត្ថប្រយោជន៍ខ្ពស់ពីរោងចក្រវារីអគ្គិសនីកំចាយដែលកំពុងសាងសង់នៅខេត្តកំពត។ ខ្សែបញ្ជូនអគ្គិសនីថ្មីនឹងតភ្ជាប់ខេត្តទាំងពីរនេះ។

បច្ចុប្បន្ននេះ អគ្គិសនីនៅទីរួមខេត្តតាកែវមានតម្លៃ ១.០០០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង (ប្រហែល ០,២៥ ដុល្លារអាមេរិកក្នុងមួយគីឡូវ៉ាត់ម៉ោង)។

## ៥. វិស័យសេវាកម្មហិរញ្ញវត្ថុមានការអភិវឌ្ឍន៍យ៉ាងល្អ

អាជីវកម្មរបស់ខេត្តតាកែវមានប្រព័ន្ធហិរញ្ញវត្ថុដែលមានការអភិវឌ្ឍន៍យ៉ាងល្អ។ ខេត្តរបស់យើងមានសាខាធនាគារចំនួន៤ ព្រមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើនទៀត។ មានអ្នកខ្ចីប្រាក់ចំនួន ៩៤.០០០ នាក់របស់ស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងខេត្តតាកែវ ស្មើនឹង ៨% នៃកម្ចីរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។





ធនាគារត្រូវបានទាក់ទាញទៅកាន់ខេត្តតាកែវដោយប្រជាជនជាច្រើនមានចំណេះដឹង និងពេញកម្លាំងផ្នែកសេដ្ឋកិច្ច។ វាមិនមែនជារឿងគួរអោយភ្ញាក់ផ្អើលទេដែលខេត្តរបស់យើង មានអត្រាភាពក្រីក្រទាបបំផុតនៅប្រទេសកម្ពុជា នេះគឺដោយសារតែការប្តេជ្ញារបស់យើង ក្នុងការលើកស្ទួយវិស័យអប់រំ។ អាស្រ័យហេតុនេះ ប្រជាជនជាច្រើនរបស់យើងមានប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ចំណាយតាមជម្រើសរបស់ពួកគេ។ ឧទាហរណ៍ ប្រជាជនរបស់យើងជាង ១៣.០០០ នាក់ មានប្រាក់តម្កល់នៅធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ។

## ៦. ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពល្អប្រសើរ

ខេត្តតាកែវមានប្រព័ន្ធស្រោចស្រពមួយចំនួនល្អបំផុតនៅក្នុងប្រទេសកម្ពុជា។ ទីតាំង ១១៤កន្លែងត្រូវបានបម្រើដោយប្រព័ន្ធស្រោចស្រពដោយមានសមត្ថភាពបង្ហូរទឹកនៅរដូវប្រាំងសរុបប្រហែល ៧០.០០០ ហិកតារ។

ការវិនិយោគធំមួយខាងផ្នែកស្រោចស្រព ត្រូវបានធ្វើឡើងកាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ ដោយមានការចូលរួមពីវិស័យឯកជនផងដែរ។ អាជីវកម្មក្នុងស្រុកមួយបានដាក់ប្រាក់វិនិយោគប្រហែល ៣០.០០០ ដុល្លារអាមេរិកដើម្បីសាងសង់ប្រព័ន្ធស្រោចស្រពឯកជនមួយ ដែលគ្របដណ្តប់លើផ្ទៃដី ១.៧៦៤ ហិកតារ។

ដោយសារតែមានហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពបែបនេះ ខេត្តតាកែវ គឺជាអ្នកផលិតស្រូវប្រាំងច្រើនជាងគេបំផុត។ ផ្ទៃដីចំនួនប្រហែល ៧០.០០០ ហិកតារ ត្រូវបានសាបព្រោះនៅក្នុងរដូវប្រាំងនាឆ្នាំ២០០៨ ដោយផ្តល់នូវទិន្នផលជាមធ្យមជិត៤,៥ តោនក្នុងមួយហិកតារ (នេះជាអត្រាខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា)។

ខេត្តតាកែវតំណាងអោយ ២២% នៃស្រូវប្រាំងនៃប្រទេសកម្ពុជា (និង ១២% នៃដំណាំស្រូវប្រចាំឆ្នាំសរុប) ទោះបីជាខេត្តមានទំហំត្រឹមតែ ២% នៃផ្ទៃដីដ៏ធំល្វឹងល្វើយរបស់ប្រទេសកម្ពុជាក៏ដោយ។

# វិស័យសំខាន់ៗរបស់ខេត្ត

## កសិកម្ម

ទោះបីជាមានទំហំតូចក៏ដោយ ខេត្តតាកែវជាអ្នកផលិតកសិផលដ៏រឹងមាំមួយនៅក្នុងប្រទេសកម្ពុជា។ ផ្ទៃដីជិត ៧០%នៃខេត្តរបស់យើងត្រូវបានប្រើប្រាស់សម្រាប់វិស័យកសិកម្ម។

តាកែវ គឺជាតំបន់ផលិតស្រូវដ៏សំខាន់មួយនៃប្រទេសកម្ពុជាដោយមានដីជាង ១៧៣.០០០ ហិកតារ និងមានប្រព័ន្ធស្រោចស្រពល្អលើផ្ទៃដីជាង ៤០% នៅក្នុងរដូវវស្សា និងមានផ្ទៃដីជាង ៧០.០០០ ហិកតារនៅរដូវប្រាំង មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់។

ទិន្នផលស្រូវនៅក្នុងខេត្តតាកែវមានកម្រិតខ្ពស់បំផុតនៅក្នុងប្រទេស (ជាមធ្យមជាង ២,៩ តោនក្នុងមួយហិកតារ នៅរដូវវស្សា និង ៤,៥ តោនក្នុងមួយហិកតារ នៅរដូវប្រាំង)។ កសិដ្ឋានដាំស្រូវប្រាំងខ្នាតធំមួយចំនួនសម្រេចបាននូវទិន្នផល ៦ តោនក្នុងមួយហិកតារ នេះគឺមួយផ្នែកដោយសារតែការវិនិយោគខាងប្រព័ន្ធស្រោចស្រព។ កសិករឈ្នះពានរង្វាន់ម្នាក់បានសម្រេចទិន្នផលជាង ៩ តោន ក្នុងមួយហិកតារ។ ការអភិវឌ្ឍន៍នេះឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តរបស់ប្រជាជនក្នុងការជ្រើសយកបច្ចេកវិទ្យាថ្មីៗ។

នៅឆ្នាំ២០០៨ ខេត្តតាកែវ បានផលិតស្រូវសរុបចំនួន ៨៧៩.៨៧៥ តោន ប្រមាណជា ១២% នៃទិន្នផលសរុបរបស់ប្រទេសកម្ពុជា និងមានលំដាប់ថ្នាក់លេខពីរ បន្ទាប់តែពីខេត្តព្រៃវែង។ ដំណាំនេះជាច្រើនត្រូវបាននាំចេញទៅខេត្តផ្សេងទៀត និងទៅកាន់ប្រទេសវៀតណាម និងទៅប្រទេសថៃ។ ម៉ាស៊ីនសម្ងួតថ្មីមួយ នឹងចាប់ផ្តើមដំណើរការនៅដើមឆ្នាំ ២០១០។ ដោយរួមផ្សំជាមួយ នឹងការអភិវឌ្ឍន៍ផ្សេងទៀត ម៉ាស៊ីននេះត្រូវបានរំពឹងទុកថានឹងបង្កើនទិន្នផលបន្ថែមទៀត។

ក្រៅពីស្រូវ ខេត្តតាកែវក៏ផលិតបន្លែក្នុងបរិមាណច្រើនផងដែរ (ប្រហែល ៧% នៃបន្លែសរុបរបស់ប្រទេសកម្ពុជា) អំពៅ (ប្រហែល ៤% នៃអំពៅសរុប) និងដំឡូងជ្វា (៤%)។ សមាគមកសិកម្ម៨ដែលសមាគមខ្លះមានជាង១០០គ្រួសារធ្វើការផលិតស្រូវដាំបន្លែបណ្តុះផ្សិត និង ផលិតចំណីសត្វ ព្រមទាំងមានការផ្តល់ឥណទានដល់សមាជិករបស់ខ្លួនផងដែរ។

ខេត្តតាកែវតំណាងអោយប្រហែល ៥% នៃការនេសាទត្រីទឹកសាបរបស់ប្រទេសកម្ពុជា ហើយក៏មានកន្លែងភ្ញាស់កូនត្រី ២៥ កន្លែងដែលភ្ញាស់បានប្រហែល ១០ លានកូនត្រីក្នុងមួយឆ្នាំសំរាប់ឧស្សាហកម្មវារីវប្បកម្មក្នុងមូលដ្ឋាន។ ខេត្តតាកែវក៏សំបូរបង្កងផងដែរ ហើយបង្កងរបស់ខេត្តយើងមានឈ្មោះល្បីល្បាញនិងមានរសជាតិឆ្ងាញ់ពិសារ។

ខេត្តតាកែវក៏មានការចិញ្ចឹមបសុសត្វច្រើនដែរ ជាពិសេស គោ ក្របី និងជ្រូក។

## ឧស្សាហកម្ម និងសេវាកម្ម

បន្ថែមពីលើមូលដ្ឋានគ្រឹះកសិកម្មដ៏រឹងមាំនេះ វិស័យឧស្សាហកម្ម និងកសិកម្មរបស់យើងកំពុងរីកលូតលាស់។ ភាពជោគជ័យរបស់យើងក្នុងការគាំទ្រដល់វិស័យអាជីវកម្មសកម្ម និងរស់រវើក កំពុងធ្វើអោយខេត្តតាកែវក្លាយជាគោលដៅឈានមុខសម្រាប់សហគ្រាសនៅក្នុងប្រទេស។ ឧទាហរណ៍ រោងចក្រកាត់ដេរបីបានរើទីតាំងទៅកាន់ខេត្តតាកែវរួចហើយ ជាពិសេសដើម្បីខិតចូលអោយកាន់តែជិតប្រភពកម្លាំងពលកម្មរបស់ខ្លួន។

សព្វថ្ងៃនេះ យើងមានមោទនភាពដែលមានសហគ្រាសឯកជនប្រហែលជាង ៦.០០០ កំពុងដំណើរការអាជីវកម្មនៅក្នុងខេត្តតាកែវរួមមាន:

| សកម្មភាព | ចំនួនសហគ្រាស |
|---|---|
| ភោជនីយដ្ឋាន និងអាហារដ្ឋាន | 307 |
| ហាងជួសជុល | 141 |
| សេវាវិជ្ជាជីវៈ | 17 |
| សេវាផ្សេងៗ | 99 |
| រោងចក្រផលិតទឹកកក | 12 |
| រោងម៉ាស៊ីនកិនស្រូវ | 15 |
| សម្ភារៈសេរ៉ាមិច | 9 |
| សិប្បកម្មខ្នាតតូចបំផុត | 4.751 |
| គ្រឿងសង្ហារិម | 1 |
| រោងចក្រផលិតឥដ្ឋ | 1 |
| រោងចក្រផលិតការ៉េម | 1 |
| សហគ្រាសផលិតនំប៉័ង | 1 |





| | |
|---|---|
| ហាងលក់រាយគ្រឿងទេស | 439 |
| ហាងលក់រាយផ្សេងៗ | 404 |
| សាកវប្បកម្ម/ដំណាំផ្ទះកញ្ចក់ | 10 |
| កសិដ្ឋានចិញ្ចឹមសត្វ | 91 |
| សម្លៀកបំពាក់ និងស្បែកជើង | 6 |
| សហគ្រាសផលិតទឹកស្អាត | 10 |
| សហគ្រាសផលិតទឹកបរិសុទ្ធ | 6 |

*ប្រភព : មូលនិធិអាស៊ី និង IFC ការចុះបញ្ជីគ្រឹះស្ថានអាជីវកម្មនៅទូរមខេត្ត និងតំបន់ទីក្រុងដែលបានជ្រើសនៅប្រទេសកម្ពុជា ខែមីនា ឆ្នាំ២០០៩ និងមន្ទីរឧស្សាហកម្មខេត្ត ។*

## កាលានុវត្តភាពអាជីវកម្ម

ខេត្តរបស់យើងផ្តល់នូវកាលានុវត្តភាពវិនិយោគជាច្រើន ដូចបានបង្ហាញពីក្រុមហ៊ុននានាដែលកំពុងប្រតិបត្តិការអាជីវកម្មនៅទីនេះស្រាប់ ។ ឧទាហរណ៍ ការអភិវឌ្ឍន៍អចលនវត្ថុដ៏ធំមួយកំពុងធ្វើឡើងនៅស្រុកគីរីវង់ ។

នេះគឺជាកាលានុវត្តភាពដ៏ល្អនៅក្នុងស្រុកនានាដែលនៅជាប់ព្រំដែនវៀតណាម ជាពិសេស ដោយសារផ្លូវថ្នល់ និងការផ្គត់ផ្គង់អគ្គិសនីកំពុងត្រូវបានកែលំអ ។

យើងមើលឃើញកាលានុវត្តភាពគួរអោយកត់សម្គាល់សម្រាប់ អាជីវកម្មក្នុងការទាញយកអត្ថប្រយោជន៍ពីកម្លាំងប្រកួតប្រជែងរបស់យើងតាមរយៈការវិនិយោគបន្ថែមទៀតនៅក្នុងវិស័យដូចខាងក្រោម:

- **កសិកម្ម និងកសិពាណិជ្ជកម្ម** ជាពិសេស រោងម៉ាស៊ីនកិនស្រូវ ក៏ដូចជារោងចក្រកែច្នៃផ្សេងទៀត ។ ទីតាំងនៅជិតទីផ្សារបន្លែរបស់វៀតណាមនៃខេត្តរបស់យើងមានលក្ខណៈទាក់ទាញជាពិសេសនិងមានកាលានុវត្តភាពសម្រាប់ការវិនិយោគឯកជនបន្ថែមទៀតខាងវិស័យស្រោចស្រពផងដែរ ។
- **ការផលិតផុនស្រាល** រួមទាំងសម្លៀកបំពាក់ ។ កម្លាំងពលកម្មតំលៃទាប និងមានចំណេះដឹង ហេដ្ឋារចនាសម្ព័ន្ធល្អ ទីតាំងជិតប្រទេសវៀតណាម និងបរិយាកាសអាជីវកម្មអំណោយផលនឹងធ្វើអោយខេត្តតាកែវក្លាយជាកន្លែងដ៏ល្អបំផុត សម្រាប់ការផលិត ។
- **ទេសចរណ៍** ខេត្តតាកែវមានបេតិកភណ្ឌបង្កប់ទុកជាច្រើន រួមទាំងតំបន់រមណីយដ្ឋានមុនសម័យអង្គរ ចាប់ពីសតវត្សរ៍ទី៥ ដល់សតវត្សរ៍ទី៨ ។ អង្គរបុរីត្រូវបានចាត់ទុកថាជា "ប្រភពនៃអរិយធម៌ខ្មែរ" ។ តំបន់រមណីយដ្ឋានផ្សេងទៀតរួមមាន ភ្នំដា ភ្នំជីសូរ សួនសត្វភ្នំតាម៉ៅ ភ្នំបាយ៉ង់... និងទន្លេបាទី ។ នៅឆ្នាំ២០០៨ ខេត្តតាកែវបានទាក់ទាញភ្ញៀវទេសចរបានប្រហែល ៥៦៩.000 នាក់ ក្នុងនោះ ១៥.១២៧ នាក់ ជាជនបរទេស ។ យើងឃើញមានកាលានុវត្តភាពគួរអោយកត់សម្គាល់ក្នុងការអភិវឌ្ឍន៍សក្តានុពលទេសចរណ៍របស់យើង ។

## សកម្មភាពអភិវឌ្ឍន៍កំពុងដំណើរការ

ទោះបីជាយើង មានមោទនភាពចំពោះសមិទ្ធផលរបស់យើងក៏ដោយ ក៏យើងនៅតែបន្តពង្រឹង និងកែលម្អភាពទាក់ទាញការវិនិយោគរបស់យើង ។ យើងនៅតែមានភាពសកម្មនៅក្នុងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធអាជីវកម្ម និងទាក់ទាញសហគ្រាសអាជីវកម្មឈានមុខមកកាន់ខេត្តរបស់យើងបន្ថែមទៀត ។ ការអភិវឌ្ឍន៍សំខាន់ៗមួយចំនួន កំពុងដំណើរការមានដូចខាងក្រោម:

- យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មមានការវិភាគវិនិច្ឆ័យ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។ យោងតាមកម្មវិធីនេះ ផលិតផលរបស់ខេត្តភាគច្រើនទទួលបាន ការគាំទ្របន្ថែម ។ ផលិតផលដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះរួមមានសម្លៀក បំពាក់ ស្បែកជើង ការផលិតផុនស្រាល ការដឹកជញ្ជូន និងទេសចរណ៍ ។ ជំនួយរួមមានការជួយសម្រួលដល់ការធ្វើ ពាណិជ្ជកម្មនិងការលើកស្ទួយវិនិយោគកំណែទម្រង់ច្បាប់ និងការកសាងសមត្ថភាពគ្រប់គ្រង និងសមត្ថភាពជំនាញក្នុងមូលដ្ឋាន ។
- ដៃគូអភិវឌ្ឍន៍ជាច្រើនកំពុងជួយដល់ការអភិវឌ្ឍន៍វិស័យឯកជន របស់ខេត្តតាកែវនៅក្នុងវិស័យសំខាន់ៗរួមមាន:

| គម្រោង | ដៃគូអភិវឌ្ឍន៍ | វិស័យ |
|---|---|---|
| គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា (USAID Cambodia MSME) | USAID | ផ្នែកឥដ្ឋក្បឿង វារីវប្បកម្ម ជ្រូក ទឹកស្អាត និងអនាម័យ ផ្លែឈើ ទឹកឃ្មុំ ជ័រទឹក ផ្នែកឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ |
| ការបង្កើនការយល់ដឹង និងការគ្រប់គ្រងជំងឺស្រូវ | ACIAR | ស្រូវ ដាំស្មៅ |
| កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា (CAVAC) | AusAID | ស្រូវ ផ្លែឈើ និងបន្លែ |
| គម្រោងផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី ដំណាក់កាលទី ២ | AusAID | កសិកម្ម |
| គម្រោងសេវាព័ត៌មាន អំពីទីផ្សារកសិកម្ម (CAMIS) | CIDA | ផ្លែឈើ និងបន្លែ |
| គម្រោងផលិតកម្មបសុសត្វរបស់អាជីវករខ្នាតតូចៗ | EU | បសុសត្វ |

## ត្រូវការស្វែងយល់បន្ថែមទៀតទេ?

សំរាប់ព័ត៌មានបន្ថែមស្ដីអំពីឱកាសវិនិយោគនិងការអភិវឌ្ឍន៍ នៅក្នុងខេត្តតាកែវ សូមទាក់ទង:

**លោក យស ណាស៊ី**
នាយខុទ្ទកាល័យខេត្ត
ខេត្តតាកែវ
ទូរស័ព្ទដៃ: (855) 012 508 549

សភាពាណិជ្ជកម្មខេត្តតាកែវ
ទូរស័ព្ទ: (855) 032 931 177 រឺ 012 814 333
Email: sophon_hum@yahoo.com

www.investincambodia.com
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - គណៈកម្មាធិការវិនិយោគកម្ពុជា

ទូរស័ព្ទ: (855) 23 981 154

www.cambodiainvestment.gov.kh
វិទ្យាស្ថានជាតិ ស្ថិតិ
www.nis.gov.kh

### ក្រសួងផាតិនានា:

ក្រសួងពាណិជ្ជកម្ម
www.moc.gov.kh
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
www.mef.gov.kh
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
www.mine.gov.kh
ក្រសួង ការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ
www.nlv.gov.kh
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
www.mlmupc.gov.kh
ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
www.mptc.gov.kh
ក្រសួងសាធារណការ និង ដឹកជញ្ជូន
www.mpwt.gov.kh
ក្រសួងទេសចរណ៍
www.mot.gov.kh
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
www.maff.gov.kh

### ផ្សេងៗ:

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
www.gmac-cambodia.org
វេទិកាវិស័យឯកជន-រដ្ឋាភិបាល
www.cambodia-gpsf.org
សភាពាណិជ្ជកម្មភ្នំពេញ
www.ppcc.org.kh

### ព័ត៌មានសង្ខេបពីខេត្តតាកែវ

| | |
|---|---|
| ប្រជាជន | 903.772 |
| សមាមាត្រការងារផ្នែកកសិកម្ម | 85% |
| ចំណាត់ថ្នាក់ភាពក្រីក្ររបស់ខេត្ត (ដែល 1 ក្រីក្រតិចតួចបំផុត) | 6/24 |
| ផ្ទៃដី | 3.563គម² |
| ដង់ស៊ីតេប្រជាជន | 254 នាក់/គម² |
| ចំនួនស្រុក/ក្រុង | 1 ក្រុង និង 9 ស្រុក |
| ចំនួនឃុំ/សង្កាត់ | 97 ឃុំ និង 3 សង្កាត់ |
| ចំនួនភូមិ | 1.118 |

### ដីខេត្តតាកែវ

ប្រភេទ : ដីសិលាល្បប់នៅផ្នែកភាគច្រើននៃខេត្ត ជាពិសេសនៅខាងកើត ។ ដីសើមដាំដំណាំ និងដីច្រោះពណ៌ក្រហម-លឿង នៅប៉ែកកណ្តាល និងប៉ែកខាងលិច ។ ដីមានជាតិអាលុយមីញ៉ូម នៅតាមព្រំដែនភាគខាងត្បូងជាមួយប្រទេសវៀតណាម ។

កម្រិតជីជាតិ : មធ្យម

### អត្រាពន្ធកម្ពុជា

| | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | 20% |
| | អត្រាលើកទឹកចិត្ត | 0% ឬ 9% |
| | | |
| ពន្ធអប្បបរមា | | 1% នៃផលរបរ |
| ពន្ធកាត់ទុក | | 15% |
| ប្រាក់ចំណូលពីការជួលអចលនវត្ថុ | | 10% |
| ការបង់ប្រាក់ជូនអនិវាសនជន | | 14% |
| | | |
| ពន្ធលើប្រាក់បៀវត្សរ៍ (រៀលក្នុងមួយខែ) | | |
| 0-500,000 | | 0% |
| 500,001-1,250,000 | | 5% |
| 1,250,001-8,500,000 | | 10% |
| 8,500,001-12,500,000 | | 15% |
| លើសពី 12,500,001 | | 20% |
| អនិវាសនជន | អត្រាថេរ | 20% |
| ពន្ធលើផលបន្ទាប់បន្សំ | | 20% |
| ពន្ធលើតម្លៃបន្ថែម | | 10% |
| | នាំចេញ | 0% |
| ពន្ធលើការផ្ទេរសិទ្ធិអចលនវត្ថុ | | 4% |

| ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចកម្ពុជា | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|
| កំណើន GDP (%) | 13.5 | 10.8 | 9.6 | 5.5 |
| កំណើននាំចេញ (%) | 12.4 | 26.9 | 10.7 | 8.8 |
| ការនាំចេញ (% GDP) | 64.2 | 68.0 | 66.7 | 68.8 |
| វិនិយោគផ្ទាល់ពីបរទេស FDI (លានដុល្លា) | 375 | 475 | 867 | 790 |
| វិនិយោគផ្ទាល់ពីបរទេស FDI (% GDP) | 6.0 | 6.5 | 6.9 | 6.0 |

## ថ្លៃអាជីវកម្ម

| ដី | លក់ (ក្នុងមួយម៉ែត្រការ៉េ) |
|---|---|
| រាជធានីភ្នំពេញ | $350-$2,000 |
| ដីពាណិជ្ជកម្ម | $30-$200 |
| តំបន់ផ្សេងទៀត | $4-$50 |
| ជនបទ | $0.50-$5 |

| ទីតាំងការិយាល័យ | ថ្លៃឈ្នួលក្នុងមួយខែ |
|---|---|
| សំខាន់ | $9-11/មួយម៉ែត្រការ៉េ |
| បន្ទាប់បន្សំ | $6-8/មួយម៉ែត្រការ៉េ |
| | |
| ថ្លៃឈ្នួលរោងចក្រ | $1.50-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |
| ថ្លៃឈ្នួលឃ្លាំង | $1.00-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |

| ថ្លៃអគ្គិសនីនៅរាជធានីភ្នំពេញ (លើកលែងតំបន់សេដ្ឋកិច្ចពិសេស) | | |
|---|---|---|
| | គីឡូវ៉ាត់ម៉ោងក្នុង ១ ខែ | តម្លៃ (រៀលក្នុង ១ គីឡូវ៉ាត់ម៉ោង) |
| ឧស្សាហកម្ម | <45,000 | 600 |
| | 45,000-130,000 | 550 |
| | >130,000 | 500 |
| | តង់ស្យុងមធ្យម | 480 |
| ពាណិជ្ជកម្ម | <45,000 | 650 |
| | 45,000-130,000 | 600 |
| | >130,000 | 500 |
| | តង់ស្យុងមធ្យម | 480 |
| ការផ្គត់ផ្គង់ហ្គាសដល់ឧស្សាហកម្ម | | $0.32/គ.ក្រ |

| តម្លៃពលកម្ម | ប្រាក់បៀវត្សរ៍ ដុល្លារក្នុងមួយខែ |
|---|---|
| អ្នកចាត់ការជាន់ខ្ពស់ | 1,000-1,500 |
| អ្នកចាត់ការមធ្យម | 500-1,000 |
| អ្នកចាត់ការកម្រិតដំបូង | 240-400 |
| គណនេយ្យករ | 250-400 |
| លេខាធិការ | 120-150 |
| ស្មៀនការិយាល័យ | 100-120 |
| អ្នកបើកបរ | 100-120 |
| អ្នកយាម | 50-80 |
| កម្មករ | 50-80 |
| ប្រាក់បៀវត្សរ៍អប្បបរមាសម្រាប់កម្មកររោងចក្រកាត់ដេរ | 60 |

# ខេត្តតាកែវ

# សក្តានុពលវិនិយោគ









Photographs by Nathan Horton www.nathanhortonphotography.com

Designed by DESIGNGROUP www.dgcambodia.com